# ដំណាំត្រកួន



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី
(ADB) លេខ 1445 - CAM (SF)
ឆ្នាំ ២០០៥

# ដំណាំត្រកួន

## I. ស្ថានភាពទូទៅ

ពូជត្រកួនមាននៅច្រើនកន្លែង និងមកពីទ្វីប ផ្សេងៗ ដូចជា តំបន់ដីសើម មានអាកាសធាតុក្តៅនៃទ្វីបអាស៊ី ភូមិភាគខ្លះនៃអាស៊ីអាគ្នេយ៍ តំបន់ខ្លះនៃទ្វីបអាហ្វ្រិក ព្រមទាំងភូមិភាគខាងត្បូង និងកណ្តាលនៃទ្វីបអាមេរិក ។

ម.ឯ.ឯ.ក AIDOC
Code: 249-017
Date:
Donated by:





វាជាដំណាំដ៏មានប្រជាប្រិយភាពនៅភូមិភាគអាស៊ីអាគ្នេយ៍ដូចជា នៅប្រទេសចិនក្រោយមកវាបានរីកពេញទូទាំងទ្វីបអាស៊ី ។ វាត្រូវរាប់បញ្ចូលទៅក្នុងគ្រួសារ Convolbulacea លំដាប់ Ipomoea ឈ្មោះវិទ្យាសាស្ត្រហៅថា Ipomoea aquatica ឈ្មោះធម្មតាអាចហៅបានច្រើនយ៉ាង Kang Kong ,Water convolvulus,Water spinach តែការនិយមប្រើជាងគេគឺ Kang Kong .... ។ តាមការបែងចែកទៅលើពណ៌របស់ផ្កាមានពីរយ៉ាងគឺ :

- *ប្រភេទទី១ :* ពណ៌របស់ផ្កាស្វាយស្រាល ដើមពណ៌បៃតងចាស់ ឬពណ៌ឈាមជ្រូក ស្លឹកតូចល្អិត ហៅថា ត្រកួនព្រៃ ។

- *ប្រភេទទី២ :* ពណ៌របស់ផ្កាស ដើមពណ៌បៃតងខ្ចី ថ្លោស ស្លឹកធំវែង

ហៅថាត្រកួនស ឬត្រកួនចិន ព្រោះពូជនេះអាចយកទៅបង្កាត់ និងផលិតជាត្រកួនគោកដាំដោយគ្រាប់ផ្ទាល់ ។ ដោយសារធាតុចិញ្ចឹម រសជាតិ ក្លិន និងងាយប្រើប្រាស់គ្រប់ពេល វាត្រូវបាននិយមចូលចិត្តច្រើនឡើងៗ ដែលគេឱ្យឈ្មោះដំណាំបន្លែយកស្លឹក ។ ត្រកួនបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនសំរាប់ទ្រទ្រង់សរីរាង្គកាយដូចក្នុងតារាងខាងក្រោម ។



តារាងអាហារូបត្ថម្ភក្នុងទំងន់ ១០០ ក្រាម បរិភោគបាន

| ផ្នែកប្រើប្រាស់ | ថាមពល | ទឹក | ប្រូតេអ៊ីន | ប្រេង | កាបូស៊ី | សរសៃ | ផេះ | Ca | Mg | Fe | VA | VC |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ខ្នាត | កាឡូរី | g | g | g | g | g | g | mg | mg | mg | mg | mg |
| ដើម - ស្លឹក | ១៣៤ | ៩០.០ | ៣.០ | ០.៣ | ៥.០ | ១.០ | ១.៦ | ៨១ | ៥២ | ៣.៣ | ៤០០០ | ១៣០ |





## II. បច្ចេកទេសដាំដុះ

ត្រកួនជាប្រភេទដំណាំមួយងាយស្រួលដាំជាងដំណាំឯទៀត ហើយដុះ

លូតលាស់មិនប្រកាន់រដូវ វាធន់ទ្រាំទៅនឹងអាកាសធាតុក្ដៅ ប៉ុន្ដែមិនធន់ទ្រាំទៅនឹងភាពរាំងស្ងួតឡើយ ។ ម៉្យាងទៀត វាក៏ជាដំណាំស្ថិតនៅក្នុងភាពធន់ទ្រាំកំរិតដីអាស៊ីត និងបាស (ជូរ ប្រៃ) ។ ប៉ុន្ដែដើម្បីឱ្យទទួលបានលទ្ធផលល្អ



គេត្រូវអនុវត្តន៍នូវវិធីសាស្ត្រជាច្រើនដូចតទៅ :

**១- ការជ្រើសរើសពូជ :**

ការជ្រើសរើសពូជសំរាប់ធ្វើការដាំដុះ វាអាស្រ័យទៅតាមវិធីសាស្ត្រនៃការដាំ ព្រោះត្រកួនគេដាំបាន២ របៀបគឺ របៀបត្រកួនគោក គេដាំដោយគ្រាប់ពូជ ប៉ុន្តែចំពោះត្រកួនស្រែ គេដាំដោយកំណាត់ទងហៅថា ស្ទូង ។

- ការជ្រើសរើសគ្រាប់សំរាប់ដាំថ្នាលគោក មានពូជជាច្រើនដែលធ្លាប់បានដាំដុះនៅប្រទេសកម្ពុជាយើង ក្នុងនោះនាំមកពីប្រទេសថៃ និងវៀតណាម ប៉ុន្តែពូជមកពីថៃដើមធំថ្លោស ពណ៌បៃតងខ្ចីរលោង ស្លឹកធំខ្លី មាន២ពូជ គឺឈ្មោះ Loet phanនិង Bai Phaiរីឯពូជមកពីប្រទេសវៀតណាមឈ្មោះ



Green Kang Kong ដើមតូចស្លីកល្អិតពណ៌បៃតងចាស់មានបន្ទាបន្តិចៗ។ គ្រាប់ពូជត្រកួនភាគច្រើនមិនត្រូវរងការបំផ្លាញដោយសត្វល្អិតឡើយ ប៉ុន្តែការទុកដាក់មិនបានត្រឹមត្រូវនៅក្នុងឃ្លាំង ធ្វើឱ្យដំណុះមានភាគរយទាប ត្រូវជ្រើសរើសយកពូជ ដែលមាន ដំណុះពី ៨៥%ឡើងទៅសំរាប់ធ្វើការដាំដុះ។



*- ការជ្រើសរើសទងសំរាប់ធ្វើពូជ :* ត្រូវកាត់ទងត្រកួនដែលថ្នាំងរបស់វាមានដុះចេញឫស ច្រើនមានប្រវែង ២៥-៣០ ស.ម មាន៣ថ្នាំងជាមធ្យមយកមករក្សាទុករយៈពេល ២-៣ថ្ងៃ ដើម្បីឱ្យការដុះឫសចេញបានកាន់តែច្រើនហើយយកទៅស្ទូងលូតលាស់លឿន ។ ក្នុង ១ ហ.ត គេប្រើទំងន់គ្រាប់ពូជជាមធ្យម ៨០-១០០គ.ក្រ តែចំពោះការដាំដោយកំណាត់ទងជាមធ្យម ២០០.០០០ កំណាត់ ។

### ២-ការជ្រើសរើស និង រៀបចំដី

ត្រកួនដុះលូតលាស់បានលើដីគ្រប់ប្រភេទ ប៉ុន្តែវាត្រូវការទឹកច្រើនជាងដំណាំឯទៀតដូចនេះ ដីសំរាប់ដាំដុះត្រកួនត្រូវមានប្រភពទឹកនៅក្បែរ



ឬដីសើមជាប្រចាំសំរាប់ត្រកួនស្រែ ។

- *ការរៀបចំដីសំរាប់ដាំគ្រាប់:* ត្រូវភ្ជួរ និងរាស់បំបែកដីព្រមទាំងប្រមូលយកស្មៅចេញឱ្យបានច្រើនសារបន្ទាប់មកលើករងឱ្យមានកំពស់ ២០-២៥ ស.ម ទទឹងរង ១០០-១២០ ស.ម ដោយយកជីធម្មជាតិលាមកសត្វគ្រប់ ប្រភេទបាចពីលើរងឱ្យបានច្រើន ១-២ បង្គីសំរាប់ផ្ទាល ១០ម² ហើយយកជី ១៥.១៥.១៥ ចំនួន ១០០-១៥០ក្រាម ដាក់បន្ថែមហើយរាស់លុបទៅក្នុងដី។

- *ការរៀបចំដីសំរាប់ត្រកួនទឹក :* ដែលហៅថា ត្រកួនស្រែត្រូវភ្ជួររាស់ដី



ស្រែមានទឹកសើមៗ មានភ្លឺព័ទ្ធជុំវិញ ។ មុននឹងរាស់ត្រូវយកជីធម្មជាតិ និងជី ១៥.១៥.១៥ ទៅបាចជាមុន បន្ទាប់មកភ្ជួរលុបទៅក្នុងដី ហើយរាស់បំបែក



ដីឱ្យល្អិតប្រមូលយកស្មៅចេញឱ្យស្អាត ។

## ៣-ការដាំដុះ

- *ការបំបែកដោយគ្រាប់ :* ដំបូងត្រូវឆ្កូតជាចង្អូរៗ ទទឹងរងដោយប្រើចន្លោះចង្អូរ ១៥ ស.ម ជំរៅ ៣-៤ ស.ម បន្ទាប់មកយកគ្រាប់ពូជទៅរោយតាមចង្អូរនោះចំងាយពីគ្រាប់មួយទៅមួយ ១-២ស.ម រួចលុបដីពីលើបន្តិចៗ និងបាចកំណាត់ចំបើងខ្ចីៗ ពីលើឱ្យជិតស្រោចទឹកឱ្យជោគរាល់ថ្ងៃ មួយថ្ងៃ



២ដង រយៈពេល ៤-៥ថ្ងៃ ត្រកួន នឹងដុះចេញផុតពីដី ។

- *ការដាំដោយកំណាត់ទង* : គឺត្រូវយកទងត្រកួនដែលបានរក្សាទុក ២-៣ថ្ងៃរួចយកទៅស្ទូងក្នុងស្រែ ដីសើមដោយប្រើចន្លោះជួរ ៤០ស.ម ចន្លោះគុម្ព ៣០ស.ម មួយគុម្ពមួយទង របៀបស្ទូងត្រូវកប់ថ្នាំងមួយចូលទៅក្នុងដី ក្រោយពីស្ទូងបាន ៥-៧ ថ្ងៃ ត្រូវបញ្ចូលទឹកឱ្យលិចរយៈពេល១យប់ បន្ទាប់មកបញ្ចេញទឹកចោលមួយភាគ ទុកមួយភាគត្រាំគល់ត្រកួនធ្វើរបៀបនេះត្រកួន

ដុះលូតលាស់លឿនឆាប់បានប្រមូលផល ។

### ៤-ការជ្រៃជ្រួយដី និង ដកស្មៅ

ការដាំដុះដោយគ្រាប់ពូជ គេត្រូវជ្រៃជ្រួយដី និងដកស្មៅក្រោយពីដាំបានរយៈពេល១០ថ្ងៃគឺដកយកស្មៅចេញហើយជ្រៃដីឱ្យផុសពីលើរងព្រមទាំងលុបគល់បន្តិច១ ធ្វើរបៀបនេះត្រកួនមានលទ្ធភាពដុះលូតលាស់កាន់តែលឿន។

*ការដាំដុះដោយកំណាត់ទង :* មិនត្រូវជ្រៃជ្រួយដីឡើយ ប៉ុន្តែគេត្រូវព្យាយាមដកស្មៅចេញពីស្រែត្រកួន រយៈពេល ១០-១៥ថ្ងៃ ក្រោយពីស្ទូង



ហើយបន្តការដករហូតដល់ត្រកួនដុះលូតលាស់ជិតដី គ្របពីលើស្មៅ ។

### ៥- ការស្រោចទឹក និងផ្តល់ជី

ត្រកួនជាប្រភេទបន្លែយកស្លឹក ដូចនេះការលូតលាស់លឿន ឬ យឺតវាអាស្រ័យទៅនឹង កំរិតនៃការផ្តល់ទឹកព្រមទាំងសារធាតុអាសូត (N) ។ដើម្បីឱ្យការលូតលាស់ទាន់ពេលវេលា គេត្រូវស្រោចទឹក ឱ្យដីសើមជានិច្ច សំរាប់ត្រកួនគោក ហើយមួយសប្តាហ៍គេត្រូវយកជីអ៊ុយរ៉េទៅលាយទឹកស្រោចម្តង ឬទឹកជីត្រាំផ្សេងក្នុងកំរិត១/២០។ ដូចគ្នានេះ ចំពោះកូនស្រែ ត្រូវបញ្ចូលទឹកឱ្យទៀតទាត់ មិនត្រូវឱ្យដីស្ងួតកាលណាដីស្ងួតធ្វើឱ្យទងត្រកួនរឹង ហើយរយៈពេល ៧-១០ថ្ងៃ គេត្រូវដាក់បន្ថែមជីអាសូតម្តង ១ហ.ត/៥០-៧០គ.ក្រ ពេលស្រែត្រកួនមានទឹកសើម។ ។

## III . អំពីជំងឺសត្វល្អិតបំផ្លាញ

ដំណាំប្រភេទនេះ ពុំមានការគ្រោះថ្នាក់ធ្ងន់ធ្ងរពីជំងឺ និងសត្វល្អិតឡើយ ប៉ុន្តែវាក៏នៅតែមានកត្តាបំផ្លាញ ខ្លះៗដែរដូចជា:

### ១- អំពីជំងឺ

ជំងឺដែលមានកើតនៅលើត្រកួនជាញឹកញាប់មានដូចជា :

- *ជំងឺពាលស្លឹក :* ធ្វើឱ្យលឿងស្លឹក ហើយស្ងួតជ្រុះស្លឹក ។
- *ជំងឺរលួយកូន :* ធ្វើឱ្យកូនត្រកួនរលួយក្រោយពីដុះបានរយៈពេល ៥-១០ថ្ងៃក្រោយដាំ ។
- *ជំងឺពកដើម ឫស :* ធ្វើឱ្យត្រកួនពកដើម ហើយឫសពកជា កង់ៗ

ច្រើនជួបជាងគេព្រមទាំងបាត់បង់ ទិន្នផលមួយចំនួន ។

ដើម្បីការពារជំងឺទាំងនេះ ត្រូវដាំដោយប្តូរដី សំអាតស្មៅឱ្យស្អាត ដាំឱ្យមានចន្លោះជួរ គុម្ពត្រឹមត្រូវហើយឆាប់ប្រមូលផល ជាពិសេសគេអាចយកគ្រាប់ពូជទៅលាយជាមួយថ្នាំសំលាប់ផ្សិតមុននឹងធ្វើការដាំដុះ។

## ២ - អំពីសត្វល្អិតស៊ីបំផ្លាញ

គេសង្កេតឃើញមានសត្វល្អិតសំខាន់ៗចំនួន ៣ប្រភេទ តែងស៊ីនិងជញ្ជក់ស្លឹក ដើម ធ្វើឱ្យបាត់បង់ទិន្នផលមួយចំនួនដូចជា :

- ***ដង្កូវហ្វូង :*** វាកាត់ស្លឹកដើម ហើយមានលក្ខណៈជាហ្វូង ឆ្លងពីស្រែមួយទៅមួយធ្វើឱ្យបាត់បង់ទិន្នផលមួយភាគធំ។

- ***ដង្កូវកន្ទុយវែង :*** ដង្កូវប្រភេទនេះស៊ីស្លឹក និងត្រួយ ខ្ចីៗលក្ខណៈផ្តុំដោយកន្លែងៗ ហើយបន្សល់ទុកទ្រនុងស្លឹក វាមានមាឌធំៗពណ៌បៃតងវែងមានកន្ទុយស្រួចវែងបះ ឡើងលើធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាពបន្លែ (ដាច់ឬរហែកស្លឹក) ។

- ***ចៃបៃតង :*** វារោមជញ្ជក់ស្លឹកដើមត្រកួនធ្វើឱ្យដើម ស្លឹករួញលែងលូតលាស់ព្រមទាំងបង្កឱ្យកើតវីរុសផ្សេងៗជាច្រើនប្រភេទ។ ដើម្បីកាត់បន្ថយនូវសត្វចង្រៃទាំងនេះ គេត្រូវមានវិធានការជាច្រើនរួមគ្នា ដូចជាការរៀបចំ ដី ប្តូរមុខ ដំណាំ ជ្រើសរើសពូជ ជ្រើសរើសរដូវ ការកំចាត់ស្មៅជាដើមព្រមទាំងគ្រប់គ្រងវត្តមានសត្វល្អិតមុនពេលវាលេចចេញនូវប្រជាករគ្រោះថ្នាក់រួមផ្សំនិងវិធានការគីមី ។

## IV . ការប្រមូលផល

គេអាចប្រមូលផលត្រកួនក្រោយពីដាំបានរយៈពេល២៨-៣៥ ថ្ងៃ។ របៀបប្រមូលផលគេធ្វើឡើងផ្សេងៗ ពីគ្នាទៅតាមតំរូវការទីផ្សារដូចជា :

- *ត្រកួនគោក* : គេដកយកទាំងឫសក្រោយពីស្រោចទឹកឱ្យជោគរយៈពេល ៣០នាទី ប៉ុន្តែខ្លះទៀតគេច្រូតត្រកួនក្បែរដីយកតែដើមខ្ចីៗទៅប្រើប្រាស់ហើយទុកគល់នៅនឹងថ្នាលដដែលបន្ទាប់មកយក ដីអ៊ុយរ៉េទៅបាចពីលើបន្តិចៗ ស្រោចទឹកឱ្យជោគព្រឹកល្ងាចតែក្នុងរយៈពេល ៧-១០ថ្ងៃគេអាចប្រមូលផលបានជាបន្តទៀត ជាមធ្យមទិន្នផលប្រមូលបានពី



៨-១០ ត/ហ.ត ។

- *ត្រកួនស្រែ :* គេកាត់ទងត្រកួនរយៈពេល ៥-៧ ថ្ងៃម្តង គេអាចប្រមូលផលបានច្រើនដង អាស្រ័យទៅនឹងការផ្តល់ជី និងទឹក ព្រមទាំងការកំចាត់ស្មៅផងដែរ ។ ត្រកួនប្រភេទនេះទទួលបានទិន្នផលខ្ពស់ជាងត្រកួនគោក ប៉ុន្តែចំពោះតំលៃលើទីផ្សារវាមានកំរិតទាបជាងត្រកួនគោក ។



